# សូមស្វាគមន៍ មកកាន់កសិដ្ឋាន រ៉ាញ់ឆូ ឡូស សឺរីតូស (Rancho Los Cerritos)

អញ្ជើញមកធ្វើដំណើរទស្សនា ប្រវត្តិសាស្ត្រ បែបវប្បធម៌ និងបែបធម្មជាតិរបស់តំបន់ នៅពេលលោកអ្នកចូលដើរលេង ក្នុងទីតាំងនេះ ! កសិដ្ឋាន រ៉ាញ់ឆូ ឡូស សឺរីតូស (Rancho Los Cerritos) ស្ថិតនៅលើទឹកដីដូនតា របស់ជនជាតិថុងវ៉ា ហើយវាជាផ្នែក នៃអំណោយដី អេស្ប៉ាញដ៏ធំធេង ។ បានកសាងឡើងនៅឆ្នាំ 1844, អគារធ្វើពីឥដ្ឋ មានរាង U នេះ បានបម្រើជា ទីស្នាក់ការកណ្ដាលរបស់កសិដ្ឋាន, អគារស្នាក់នៅ, និងផ្ទះឯកជន ។ សព្វថ្ងៃនេះ ផ្ទះធ្វើពីឥដ្ឋនេះនិទានរឿង គួរជាទីជាប់ចិត្តនានា របស់អ្នកដែលបានហៅវាថា ផ្ទះពួកគេ អស់រយៈពេលជាច្រើនឆ្នាំ ខណៈដែលសួនច្បារ ផ្ដល់ជាលំហរ សម្រាប់ឱ្យគេអាច សម្រាកលំហែរព្រមទាំង ជាជម្រក សម្រាប់បក្សី ដើមកំណើតនៅទីនេះ និងបក្សីព្រនេចរ មេអំបៅ និងសត្វក្រីតជី (critters) ផ្សេងៗ ទៀត ។




កសិដ្ឋាន រ៉ាញ់ឆូ ឡូស សឺរីតូស (Rancho Los Cerritos) គឺជា ទីតាំងភូមិសាស្ត្រ ជាប្រវត្តិសាស្ត្រ នៅកម្រិតមូលដ្ឋាន កម្រិតរដ្ឋ និងកម្រិតជាតិ ។ ទីតាំងបើកដំណើរការជូនសាធារណជន ពីថ្ងៃពុធ ដល់ថ្ងៃអាទិត្យ ។ ការបើកទទួល ដំណើរទស្សនាចរណ៍ និង ចំណត មិនត្រូវបានគិតប្រាក់នោះទេ ដោយសារមានអំណោយសប្បុរសធម៌ ជាបន្តបន្ទាប់ ។ អំណោយទាំងនេះ ក៏ទ្រទ្រង់ដល់កម្មវិធីពិព័រណ៍ លក្ខណៈនវានុវត្តន៍, កម្មវិធីអប់រំ លំដាប់ម្ចាស់ជ័យលាភី, និងសកម្មភាពអភិរក្ស ជាច្រើនទៀត របស់ទីតាំងនេះផងដែរ ។

សូមភ្ជាប់ទំនាក់ទំនង ជាមួយយើងខ្ញុំ នៅលើបណ្ដាញសង្គម ហើយចូលរួម ក្នុងបញ្ជីផ្ញើអ៊ីមែល របស់យើងខ្ញុំ (www.rancholoscerritos.org) សម្រាប់ព្រឹត្តិការណ៍ ដែលនឹងមកដល់ នាពេលឆាប់ៗ នេះ ។ ព័ត៌មានអំពីសមាជិកភាព, ការជួលទីតាំង, និង ឱកាសស្ម័គ្រចិត្ត អាចរកបាន នៅមជ្ឈមណ្ឌលទទួលភ្ញៀវ ។

## សួនច្បារអ្នកស្រុក កាលីហ្វ័រញ៉ា [California Native Garden] (A)



*ទីតាំងភូមិសាស្ត្រប្រវត្តិសាស្ត្រ (Historic Marker)*

នៅជិតច្រកចូល ទៅសួនច្បារអ្នកស្រុក កាលីហ្វ័រញ៉ា មានស្លាកបង្ហាញពីឋានៈរបស់ទីតាំង ជាទីតាំងប្រវត្តិសាស្ត្រ ដែលមានចុះបញ្ជី នៅកាលីហ្វ័រញ៉ា #978 ។ ផ្នែកនេះរបស់ទីតាំង ពីដើមឡើយ មានគ្របទៅដោយ ស្មៅដុះក្នុងស្រុក និងព្រៃគម្ពោតដែលដុះតាមតំបន់ឆ្នេរ ។ ក្នុងទសវត្សរ៍ ឆ្នាំ 1930 រ៉ាហ្វ ខននែល ស្ថាបត្យករផ្នែកទេសភាព (landscape architect Ralph Cornell) បានរៀបចំ សួនច្បាររុក្ខជាតិ ក្នុងស្រុក និងផ្លែកៗ មកពីក្រៅ ជូន អាវីស & លេវេលលីន ប៊ិកប៊ិ ស៊ីញ៉ឺ (Avis & Llewellyn Bixby Sr.) ដែលបានជួយបង្ការ ការច្រោះបាក់ដី ដែលបង្កឡើងដោយទឹកភ្លៀង ។ កសិដ្ឋាន រ៉ាញ់ឆូ ឡូស សឺរីតូស (Rancho Los Cerritos) នៅបន្តដោះស្រាយបញ្ហានោះ តាមរយៈគម្រោងគ្រងទីករបស់យើង ***ដោយពិនិត្យមើលពីអតីតកាល ដើម្បីឈានឆ្ពោះទៅមុខ*** ។

នៅពេលលោកអ្នកដើរមើលតាមផ្លូវដី លោកអ្នកនឹងសង្កេតឃើញ ចង្អូរមួយចំនួន ដែលឱ្យយល់បាន ពីរបៀប និងមូលហេតុ ដែលទីតាំងនេះត្រងយកទឹកភ្លៀង ។ ក្នុងចម្ងាយ ប្រមាណ ដប់យ៉ាត ពីចង្អូរ ទីមួយ, ដើមឈើតូច នៅខាងឆ្វេងដៃលោកអ្នកនោះ គឺជា ដើមកាតាលីណា អាយអ៊ឺនវូត (Catalina ironwood) ។ ឈ្មោះ អាយអ៊ឺនវូត (ironwood) ផ្ដើមចេញពី សភាពព្រៃក្រាស់ ។ ជនជាតិដើម រស់នៅក្នុងតំបន់នេះ គឺជនជាតិថុងវ៉ា (The Tongva) បានប្រើដើម និងមែក របស់ឈើប្រភេទនេះ សម្រាប់ធ្វើឧបករណ៍ ដងគ្រាប់ព្រួញ និង ចង្វារទូកកានូ ។ ទោះបីជាព្រៃមានសភាពក្រាស់ក្ដី វាមានលក្ខណៈអណ្ដែតលេចចេញមក ។

អំបូររក្សាលំនឹងបរិស្ថាន (keystone species) របស់តំបន់នេះ គឺ ដើមស៊ីកាម័រ (sycamore) ដែលដើមវាមានសំបកពណ៌សលក្ខណៈប្លែកខុសពីគេ ។ ម្លប់ ពីដើមស៊ីកាម័រ (sycamore) មានភាពទាក់ទាញស្វាគមន៍ ទោះបីជានៅពេលថ្ងៃក្ដៅក្ដី ។ នៅសងខាងផ្លូវដើរ លោកអ្នកនឹងសង្កេតឃើញ ចុលព្រឹក្ស ខ្ពស់ៗ ដែលមានស្លឹកតូចៗ ខៀវស្រងាត់ ។ នៅរដូវផ្ការីក ដើមសេអាណូត (Ceanothus) កាត់ពូជនេះ មានលំអ ទៅដោយកញ្ចុំផ្កាតូចៗ ពណ៌ស្វាយ ចេញខៀវ (purple-blue flowers) ។ ជនជាតិថុងវ៉ា (The Tongva) បានប្រើប្រាស់ មែកសេអាណូត (Ceanothus) ជាចបជីក ។ ពួកគេបានប្រើប្រាស់ ផ្កាសេអាណូត (Ceanothus) ដែលជាពពុះ (lather) ធ្វើជាសាប៊ូ ។



*ផ្កាសេអាណូត (Ceanothus) រដូវផ្ការីក*



*ដើមអ៊ែលឌឺ ប៊ែរី (Elderberry Tree)*

នៅខាងស្ដាំ ផ្នែកខាងចុង នៃវង់នេះ, ដើមសែនមកពីតំបន់ឆ្នេរ (coast live oak) នៅតែផ្ដល់ជាម្លប់ យ៉ាងត្រឈឹងត្រឈៃ ។ ដោយសារមនុស្ស និងដើមសែន មានទំនោររលូតលាស់ នៅក្នុងបរិស្ថាន ប្រហាក់ប្រហែលគ្នា, ផ្លែសែន បានបម្រើជា អាហារមូលដ្ឋាន របស់អារ្យធម៌នានា នៅជុំវិញពិភពលោក ។ ជនជាតិថុងវ៉ា (The Tongva) *ក្រោយពេលធ្វើដំណើរការ ជុំវិញដែនវង់នេះរួច សូមបន្តដំណើរឡើងជណ្ដើរ នៅខាងឆ្វេងដៃ របស់លោកអ្នក ដើម្បីចាកចេញ ពីសួនច្បារនេះ ។*

នៅផ្នែកខាងលើជណ្ដើរ មានដើមអ៊ែល ប៊ែរី (elderberry) នៅខាងស្ដាំដៃលោកអ្នក ។ ជនជាតិថុងវ៉ា (The Tongva) បានហៅវាថា ជា «ដើមភ្លេង» ដោយសារគេអាចយក មែក និងធាង របស់វា ទៅធ្វើជា ដងគោះសម្លេង (clapper sticks) ខ្លុយ និង កញ្ចែ ។ ជនជាតិថុងវ៉ា (The Tongva) ក៏ត្រូវបានប្រើប្រាស់ ផ្កាអ៊ែល ប៊ែរី (elderberry) ជាឱសថព្យាបាល និងផ្លែរបស់វា ដើម្បីផ្ដល់រសជាតិផ្អែម ក្នុងអាហារផងដែរ ។ *សូមបន្តដំណើរទៅ ផ្ទះធ្វើពីឥដ្ឋ ។*

*នៅពេលលោកអ្នកធ្វើដំណើរទស្សនាចរណ៍ នៅផ្ទះធ្វើពីឥដ្ឋ នៃកសិដ្ឋាន រ៉ាញ់ឆូ ឡូស សឺរីតូស (Rancho Los Cerritos adobe) សូមដើរមើលទីធ្លា តាមទិសបញ្ច្រាស់ ទ្រនិចនាឡិកា ហើយពិនិត្យមើល ជំហាន របស់លោកអ្នក នៅលើស្មាដៃដុំឥដ្ឋ ជាប្រវត្តិសាស្ត្រនេះ ។ ប្រសិនបើលោកអ្នកចង់ប្រើប្រាស់ ជណ្ដើរយន្ត ADA ដើម្បីចូលទៅ ទីធ្លានោះ សូមស្នើសុំជំនួយ ។*

# ផ្ទះធ្វើពីឥដ្ឋ [The Adobe] (B)

ដីនៃកសិដ្ឋាន រ៉ាញ់ឆូ ឡូស សីរីតូស (Rancho Los Cerritos adobe) គឺជាស្នាដៃមួយ នៃស្នាដៃស្ថាបត្យកម្ម មួយចំនួនដែលនៅសេសសល់ ក្នុងបែបផែនសម័យអាណានិគម ម៉ុនតេរ៉េយ៍ (Monterey Colonial style architecture) នៅកាលីហ្វ័រញ៉ា ប៉ែកខាងត្បូង ។ អគាផ្ទះធ្វើពីឥដ្ឋ ត្រូវបានសាងសង់ដោយពលករជនជាតិដើម សម្រាប់ជា ទីស្នាក់ការកណ្តាល សម្រាប់កសិកដ្ឋានចិញ្ចឹមពាហនៈ របស់ រ៉ាហ្វាអ៊ែលឡា & ចន ថែមផល (Rafaela & John Temple) នៅឆ្នាំ 1844 ។ ផ្ទះគោលកម្ពស់ពីរជាន់ មាន រានហាលព័ទ្ធជុំវិញ បង្អួចកញ្ចក់ និងទ្វាឈើ ។ នៅក្បែរ ស្លាបកន្លែងធ្វើការ មានច្រកផ្លូវដើរនៅខាងក្រៅ និងផ្ទៃបាតជាដី ។ ដំបូល មានលក្ខណៈរាបស្មើ និងប្រេក់ ដោយកៅស៊ូ (កៅស៊ូ ចាក់ថ្នល់) ។ ជញ្ជាំង មានកម្រាស់ ពីរហ្វីត នៅស្លាបកន្លែងធ្វើការ និង ជិត បីហ្វីត នៅជាន់ក្រោមរបស់ផ្ទះគោល ។ ដុំឥដ្ឋ ហាលសម្ងួត ដោយពន្លឺព្រះអាទិត្យ របស់ផ្ទះធ្វើពីឥដ្ឋ ត្រូវបានធ្វើឡើង ពីដី ចម្បើង ដីខ្សាច់ និងទឹក ។ ផ្ទះនេះ ត្រូវបានធ្វើឱ្យទំនើបឡើង ដោយស្ថាបត្យករ ឈ្មោះ ឃីននែត វីង (Kenneth Wing) ក្នុងទសវត្សរ៍ ឆ្នាំ 1930 ជាផ្ទះឯកជនសម្រាប់ អាវីស & លេវេលលីន ប៊ិកប៊ី ស៊ីញ៉ូ (Avis & Llewellyn Bixby Sr.) ។ នវានុវត្តន៍នេះ បានរួមបញ្ចូលធាតុនានា នៃបែបផែនស្ថាបត្យកម្ម មិសសុន រីវ៉ាយវ៉ល () រួមទាំង ដំបូលប្រក់ក្បឿងក្រហម និងច្រកផ្លូវដើរ មានប្រក់ដំបូល ។ សេវាទឹក អគ្គិសនី កម្តៅ, ការកែពង្រឹងគ្រោងផ្ទះបង្ការពេលរញ្ជួយដី (seismic retrofitting) និងរានហាល មានប្រក់ដំបូល (sunporch) ត្រូវបានបំពេញបន្ថែម នៅពេលនោះ ។



*ទីធ្លា (1872)*

**បរិវេណទីធ្លា ៖** តាមការសាងសង់ ពីដើមដំបូងមក ស្លាបកន្លែងធ្វើការ រួមមាន បន្ទប់របស់មេកា បន្ទប់គេង និងបន្ទប់ទទួលទាន សម្រាប់ពលករកសិដ្ឋាន ។ ក៏មាន រោងជាងដែក និង បន្ទប់ជាឃ្លាំង មួយចំនួន សម្រាប់ដាក់អុស អាហារ គ្រឿង និងឧបករណ៍ ប្រើប្រាស់នានា ។ ផ្ទះគោល មាន បន្ទប់ទទួលភ្ញៀវ និងបន្ទប់ទទួលទាន នៅជាន់ផ្ទាល់ដី ព្រមទាំង បន្ទប់គេង មួយចំនួន នៅជាន់លើ ។ ជាន់ទីពីរ និងជណ្តើរ នៅក្នុងអគារ មានសណ្ឋាន ប្លែកភ្នែក ប្រើឥដ្ឋ (adobe) ។ ទ្វារចូលទីធ្លា អាចចាក់សោរបាន នៅពេលយប់ ដើម្បីរក្សាសន្តិសុខ ។ ដោយធ្លាប់ជារោងធ្វើការ ពោរពេញទៅដោយធូលី ស្ងួត, ទីធ្លានេះត្រូវបានរៀបចំសណ្ឋានឡើង នៅពេលធ្វើនវានុវត្តន៍ ក្នុងទសវត្សរ៍ ឆ្នាំ 1930 ។

**បន្ទប់របស់មេការ ៖** ដោយសារ រ៉ាហ្វាអ៊ែលឡា & ចន ថែមផល (Rafaela & John Temple) បានរស់នៅក្នុងឡូស អ៊ែនជីឡេស ដែលត្រូវធ្វើដំណើររយៈពេល កន្លះថ្ងៃ តាមរថភ្លើង ទើប *ម៉ាយ៉កដូម៉ូ [mayordomo]* (មេកា ឬអ្នកគ្រប់គ្រង) ត្រូវបានជួល ឱ្យមើលការខុសត្រូវ លើប្រតិបត្តិការ ប្រចាំថ្ងៃ នៅកសិដ្ឋានចិញ្ចឹមពាហនៈ ។ ជំរឿនឆ្នាំ 1850 របស់ខោនធី ឡូស អ៊ែនជីឡេស បានចុះបញ្ជី ជនអន្តោប្រវេសន៍ ដើមកំណើតអេស្ប៉ាញ ឈ្មោះ ចូស សាយម៉ុន រ៉ុកកូ (Jose Simon Roco) ជាអ្នកគ្រប់គ្រងកសិដ្ឋាន ។ ជំរឿន ក៏បង្ហាញថា កសិដ្ឋាន រ៉ាញ់ឆូ ឡូស សីរីតូស (Rancho Los Cerritos) មានពលករ ជាបុរស ចំនួន 16 នាក់ នារី 7 ចំនួន នាក់ និងកុមារ 12 ចំនួន នាក់ ។ បរិវេណនេះ បានក្លាយទៅជា ឃ្លាំងសម្រាប់ដាក់ឥវ៉ាន់ នៅទសវត្សរ៍ ឆ្នាំ 1930 ។

**បន្ទប់បោកគក់ ៖** ម៉ាហ្គារ៉េត & ចូថែម ប៊ិកប៊ី (Margaret & Jotham Bixby) បានចូលមករស់នៅ ក្នុងផ្ទះធ្វើពីឥដ្ឋនេះ នៅពេល ហ្វ្លីន, ប៊ិកប៊ី & ខូ (Flint, Bixby & Co.) បានទិញអចលនទ្រព្យនេះ នៅឆ្នាំ 1866 ។ គ្រួសារ ប៊ិកប៊ី (Bixbys) បានជួល ជនអន្តោប្រវេសន៍ ដើមកំណើតចិន ចំនួនពីរនាក់ គឺ អាអឹង និង អាហ្វាន់ ឱ្យបម្រើការងារ នៅក្នុងផ្ទះ នៅកសិដ្ឋាន រ៉ាញ់ឆូ ឡូស សីរីតូស (Rancho Los Cerritos) ក្នុងទសវត្សរ៍ ឆ្នាំ 1870 យោងតាមសេចក្តីកត់ត្រា អំពី *ថ្ងៃ នៅផ្ទះធ្វើពីឥដ្ឋ [Adobe Days]* (1925) ដែលសរសេរ ដោយ សារ៉ា ប៊ិកប៊ី ស្ម៊ីត (Sarah Bixby Smith) ។ កិច្ចការប្រើកម្លាំងបាយ របស់ អាអឹង & អាហ្វាន់ រួមមាន ការងារបោកគក់ និង ចម្អិនអាហារ ។ ទំនិញរោងចក្រថ្មីៗ ដែលអាចរកបាននោះ បានកាត់បន្ថយបន្ទុកការងារ ប៉ុន្តែ ទឹកនៅតែត្រូវដងចេញពីអណ្តូង ហើយដែក នៅតែត្រូវដុត នៅក្នុងចង្រ្កានលុតដែក ។ នៅទសវត្សរ៍ ឆ្នាំ 1930, បន្ទប់នេះ បានក្លាយទៅជា បន្ទប់ងងឹត សម្រាប់ លេវេលលីន ប៊ិកប៊ី ស៊ីញ៉ូ (Llewellyn Bixby Sr.) ដោយសារគាត់ជា អ្នកចូលចិត្តថតរូប (amateur photographer) ម្នាក់ ។



*បន្ទប់ទឹក ក្នុងអំឡុងទសវត្សរ៍ ឆ្នាំ 1930 ៖*

**ឃ្លាំង ៖** មានមនុស្សពីម្ភៃ ទៅ សាមសិបនាក់ជាង បានរស់នៅ ក្នុងកសិដ្ឋាននេះ ក្នុងសតវត្សរ៍ ទី 19 ហើយជារឿយៗ ភ្ញៀវបានមកស្នាក់អាស្រ័យ ម្តងៗរាប់សប្តាហ៍ ។ ហេតុនេះហើយ ទើបមានបន្ទប់ច្រើន នៅស្លាបកន្លែងធ្វើការ ដើម្បីទុកដាក់ ចំណីអាហារ គ្រឿងសង្ហារឹមបន្ថែម បរិក្ខារទឹកដោះគោ អុស និង គ្រឿងសម្ភារៈផ្គត់ផ្គង់ផ្សេងៗទៀត ក្នុងបរិមាណច្រើនៗ ។ ពីដើមឡើយ មានបីបន្ទប់ ដែលផ្នែកនេះ នៃស្លាបកន្លែងធ្វើការ បានក្លាយទៅជា បន្ទប់ស្នាក់នៅ សម្រាប់ភ្ញៀវ ចំនួន ពីរបន្ទប់ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ 1930 ដែលបន្ទប់នីមួយៗ មានបន្ទប់ទឹក និង ទូ រៀងៗ ខ្លួន ។

**រោងជាងដែក ៖** បំពង់បង្ហុយខ្យល់ រាងដូចជីវឡារ ស្ថិតនៅផ្នែកខ្ពស់ នៃជញ្ជាំង បង្ហាញថា កន្លែងនេះ ពីដើមឡើយ ធ្លាប់ជារោងជាងដែក ។ ដោយសារគ្មាន ជាងដែក ចុះបញ្ជី នៅក្នុងជំរឿន ឆ្នាំ 1850, ប្រាកដជា អ្នកគង្វាលសេះ (អ្នកជិះសេះ) បានបង្កើត និងបំពាក់ ស្បែកជើង ឱ្យសេះ ។ ពលករ របស់កសិដ្ឋាន ក៏អាចបានធ្វើការ ជួសជុលឧបករណ៍, ដូរបាតស្បែកជើងករ៉ែង, ធ្វើគ្រឿងសង្ហារឹម និងសំលៀងកាំបិត នៅទីនេះ ផងដែរ ។ នៅអំឡុងទសវត្សរ៍ ឆ្នាំ 1930, បន្ទប់នេះ បានក្លាយទៅជា បន្ទប់ទទួលភ្ញៀវ ដែលមានឡដុតកម្តៅ និងធ្នើដាក់សៀវភៅ ជាប់ជញ្ជាំង ។ ទ្វា នៅឯនាយ ជ្រុងខាងឆ្វេង ដែលមានបាំង ដោយគំនរបន្ទះក្តារនោះ នាំទៅរក បន្ទប់គេង ដែលនៅក្បែរនោះ ។

**បន្ទប់គេង** ៖ ក្នុងពេលធ្វើនវានុវត្តន៍ នៅអំឡុងទសវត្សរ៍ ឆ្នាំ 1930, បន្ទប់នេះ បានក្លាយទៅជា អង្គឯកតាផ្ទះ មាន បីបន្ទប់ (three-room suite) សម្រាប់កូនប្រុស របស់ អាវីស & លេវេលលីន ប៊ិកប៊ី ស៊ីញ៉ូ (Avis & Llewellyn Bixby Sr.) ។ នោះរួមមាន បន្ទប់ទទួលភ្ញៀវ បន្ទប់គេង និងបន្ទប់ទឹក ។ វាក៏មាន ប្រព័ន្ធអគ្គិសនី ទឹក និងកម្តៅផងដែរ ។ បង្អួចមានរាងដូចជីវឡារ ដែលស្ថិតនៅផ្នែកខ្ពស់ នៃជញ្ជាំង បង្ហាញថា បង្អួចនេះ ធ្លាប់ជា ផ្នែកនៃ រោងជាងដែក ។



*រានហាល មានប្រក់ដំបូល (1954)*

**បណ្ណាល័យ ៖** ក្នុងពេលធ្វើនវានុវត្តន៍ នៅអំឡុងទសវត្សរ៍ ឆ្នាំ 1930, បន្ទប់ ចំនួនបី ត្រូវបានប្រែក្លាយឱ្យទៅជា បណ្ណាល័យ ដ៏ធំនេះ ដែល អាវីស & លេវេលលីន ប៊ិកប៊ី ស៊ីញ៉ូ (Avis & Llewellyn Bixby Sr.) ចូលចិត្ត អាន ស្តាប់វិទ្យុ និងលេង ល្បែងរកពាក្យ ។ សៀវភៅនៅបណ្ណាល័យ ដែលមានតាំងបង្ហាញនេះ ជាផ្នែកនៃ កម្រងឯកសារយោង មិនអាចខ្ចីចេញក្រៅបាន ដែលមានរៀបចំជាកាតាឡុក តាមរយៈ បណ្ណាល័យសាធារណៈ ឡុងប៊ិច ។ (ការណាត់ជួប អាចធ្វើទៅបាន ដើម្បីប្រើប្រាស់ សៀវភៅទាំងនេះ សម្រាប់ការស្រាវជ្រាវ ។)

**រានហាល មានប្រក់ដំបូល (sunporch) ៖** ដោយមានបន្ថែម នៅក្នុងទសវត្សរ៍ ឆ្នាំ 1930 រានហាល មានប្រក់ដំបូលនេះ តភ្ជាប់ ផ្ទះគោល ទៅនឹង បណ្ណាល័យ (នៅស្លាបខាងត្បូង) និងផ្តល់ជាផ្លូវចូលទៅ ផ្ទះបាយ (នៅស្លាបខាងជើង) ។ វាអនុញ្ញាតឱ្យគេអាចទស្សនា ទេសភាពទីធ្លា បែបលំហែ ក្នុងគ្រប់ប្រភេទអាកាសធាតុបាន ។ ក្នុងអំឡុងសតវត្សរ៍ ទី 19 ច្រកចូល ផ្ទះគោល គឺតាមផ្លូវចូលកណ្តាល ដែលនាំឆ្ពោះ ជណ្តើរ និង ផ្លូវដើរ ក្នុងផ្ទះ ។ ចម្រឹង ដែលលោកអ្នកមើលឃើញ នៅផ្នែកខាងក្នុងបង្អួច របស់បន្ទប់រានហាល មានប្រក់ដំបូល បង្ហាញថា វាធ្លាប់ជាផ្នែកខាងក្រៅ របស់បង្អួច មុនពេលគេបន្ថែម រានហាល មានប្រក់ដំបូល ។ ការពិតដែលថា ចម្រឹងដែកទាំងនេះ មិនត្រូវបានគេយកចេញ ក្នុងពេលធ្វើនវានុវត្តន៍ លើផ្ទះធ្វើពីឥដ្ឋនោះ បង្ហាញពី ការពេញចិត្ត របស់គ្រួសារនេះ ទៅលើប្រវត្តិសាស្ត្រ របស់ផ្ទះនេះ ។

**បន្ទប់ទទួលភ្ញៀវ ៖** នៅក្នុងផ្ទះ ពីសម័យសតវត្សរ៍ ទី 19 ជាទូទៅ បន្ទប់ទទួលភ្ញៀវ គឺជាកន្លែងជួបជុំគ្នា ពេលសម្រាក របស់សមាជិកគ្រួសារ និងភ្ញៀវ ។ បន្ទប់ទទួលភ្ញៀវ របស់ ប៊ិកប៊ី (Bixbys) នេះ មានរលេចទៅដោយ ក្រដាសបិទជញ្ជាំង កាលពីសម័យទសវត្សរ៍ ឆ្នាំ 1870, សៀវភៅ និង ស្នាដៃសិល្បៈ ព្រមទាំង ចង្ក្រានកម្ដៅ ហ្វ្រែងគ្លីន (Franklin stove) ។ ដោយចាប់ផ្ដើម តាំងពីទសវត្សរ៍ ឆ្នាំ 1880 មក, ផ្នែកតូចៗ នៃផ្ទះធ្វើពីឥដ្ឋនេះ ត្រូវបានជួល ដោយអ្នកបម្រើការងារ នៅតាមកសិដ្ឋាន និងទីតាំងផលិតទឹកដោះគោ នៅជាតិខាងនោះ ។ ម៉ាន្វែអ៊ែល & ខុងសិបស្យុង លីយេរ៉ា (Manuel & Concepción Liera) គឺជាគ្រួសារ មួយ ក្នុងចំណោមគ្រួសារអ្នកជួល នៅក្នុងទសវត្សរ៍ ឆ្នាំ 1920 ដែលបានជួលបន្ទប់នេះ និងបន្ទប់មួយទៀត នៅខាងលើបន្ទប់នេះ ។ ពិធីជប់លៀង របស់ស្វាមីភរិយានេះ បានរៀបចំឡើង នៅជាន់ខាងលើ ក្នុងឆ្នាំ 1924 ដែលមានការរៀបចំភ្លើងបំភ្លឺ អគ្គិសនី ដោយក្លឹបខោនធី រីជីនញៀ ដែល ម៉ាន្វែអ៊ែល លីយេរ៉ា (Manuel Liera) បានបម្រើការងារ ជាអ្នកថែសួន ។ ក្នុងទសវត្សរ៍ ឆ្នាំ 1930 ផ្នែកនេះ នៃផ្ទះធ្វើពីឥដ្ឋ បានក្លាយទៅជា បន្ទប់ទទួលភ្ញៀវ មានពីរជាន់ ។ ការស្ដារបន្ទប់នេះឡើងវិញ នាពេលបច្ចុប្បន្ន ទទួលបានមូលនិធិ ពី***យុទ្ធនាការបើកទ្វារ*** របស់កសិដ្ឋាន រ៉ាញ់ឆូ ឡូស សឺរីតូស (Rancho Los Cerritos' Opening Doors campaign) ។

**ជណ្ដើរ និងផ្លូវដើរក្នុងផ្ទះ ៖** ផ្នែកកណ្ដាល នៃផ្ទះធ្វើពីឥដ្ឋ របស់ រ៉ាហ្វាអ៊ែលឡា & ចន ថែមផល (Rafaela & John Temple) មានកម្ពស់ ដល់ជាន់ទីពីរ ដែលមានផ្លូវដើរ និងជណ្ដើរ នៅក្នុងផ្ទះ ។ ស្ថាបត្យកម្ម ប្រភេទនេះ មានលក្ខណៈស្រដៀងគ្នានឹង ចន ថែមផល ដែលមានកំណើត នៅម៉ាសាជូសែត (Massachusetts-born John Temple) ខណៈដែលគ្រឿងសំណង់ ចំបង ធ្វើពីដុំឥដ្ឋ បានពីដីហាលថ្ងៃ គឺជា សណ្ឋានលក្ខណៈ របស់តំបន់នេះ ។ បន្ទប់គេង ស្ថិតនៅជាន់ខាងលើ ។

**បន្ទប់ទទួលទាន ៖** នៅពេលពេញមួយសតវត្សរ៍ ទី 19សមាជិកគ្រួសារ និងភ្ញៀវរបស់ពួកគេ បានទទួលទានអាហារ នៅក្នុងបន្ទប់ទទួលទាននេះ ខណៈដែលពលករកសិដ្ឋាន បានទទួលទានអាហារ នៅបន្ទប់ទទួលទានបុរស (ស្លាបខាងជើង) ។ បន្ទប់ទទួលទាន មានបំពាក់ទៅដោយសម្ភារៈ ដូចកាល នៅក្នុងទសវត្សរ៍ ឆ្នាំ 1870 ។ ចុងភៅ នៅពេលនោះ គឺ អាអ៊ីង និង អាហ្វាន់ ដែលក៏ទទួលខុសត្រូវ លើការងារបោកគក់ (ដូចមានបញ្ជាក់ខាងលើរួច) ផងដែរ ។ ពួកគេប្រើប្រាស់ ចង្ក្រានដុតអុស នៅក្នុងផ្ទះបាយនៅជាប់គ្នា និង ហនល្លូ [horno] (ឡចង្ក្រានដី) នៅក្នុងទីធ្លា ដើម្បីរៀបចំអាហារ សម្រាប់គ្រួសារ និងពលករកសិដ្ឋាន ។ នៅផ្ទះបាយមានពីរកន្លែង ដោយមានកន្លែងរស់នៅ សមល្មម សម្រាប់ចុងភៅ (គ្រែតថ្នាក់លើគ្នា) ។ ក្នុងពេលធ្វើនវានុវត្តន៍ ក្នុងទសវត្សរ៍ ឆ្នាំ 1930 បន្ទប់ទទួលទាន របស់បុរស ត្រូវបានជំនួស ដោយផ្ទះបាយទំនើប ហើយ ឃ្លាំងស្បៀង របស់មេការក្នុងផ្ទះ បានជំនួស ផ្ទះបាយ កាលពីទសវត្សរ៍ ឆ្នាំ 1870 ។ *ចេញពីរានហាល មានប្រក់ដំបូល (sunporch) ទៅ សូមត្រឡប់ទៅ ច្រកទ្វារទីធ្លាវិញ ។ ផ្លូវដើរនៅក្នុងចម្ការ ចាប់ផ្ដើមចេញពីផ្នែក នៅហួសស្គូកឈើ [wooden caretta] (រទេះគោ) បន្តិច ដែលរទេះនេះបានធ្វើឡើង ដោយកូនសិស្សជាងឈើ នៅវិទ្យាល័យ ខមថុន (Compton High School) ។*

## ចម្ការ (C)


*ដើមម៉ាកាដាមៀ*
*(macadamia tree)*

សួនច្បារដើម របស់ រ៉ាហ្វាអ៊ែលឡា & ចន ថែមផល (Rafaela & John Temple) អាស្រ័យ ទាំងស្រុង លើដើមឈើហូបផ្លែ និងលតាវល្លិ៍ ដែលអាចរកបាន នៅក្នុងស្រុក ដូចជា ដើមក្រូចមិសសុន (mission oranges) ដើមក្រូចឆ្មាលឿង ដើមទំពាំងបាយជូរ និងដើមទទឹម ។ នៅក្នុងទសវត្សរ៍ ឆ្នាំ 1930 រ៉ាហ្វ ខននែល ស្ថាបត្យករផ្នែកទេសភាព (landscape architect Ralph Cornell) បានរៀបចំចម្ការមួយ នៅប៉ែកខាងត្បូងផ្ទះធ្វើពីឥដ្ឋនេះ ។ ការកំណត់ទីតាំងចម្ការ បានជានាថា ដើមឈើហូបផ្លែ ប្រកបដោយម្លប់ត្រឈឹងត្រឈៃ នឹងជួយផ្ដល់ភាពត្រជាក់ ដល់ផ្ទះធ្វើពីឥដ្ឋ នៅផ្នែកនេះ នៅពេលអាកាសធាតុឡើងក្ដៅ ។ *ផ្លូវដើរ កាត់តាមចម្ការ នាំទៅដល់ ទីធ្លាផ្នែកខាងក្រោយ ។ ជាជម្រើសផ្សេងទៀតលោកអ្នកអាចចូលទៅ ទីធ្លាផ្នែកខាងក្រោយបាន តាមទីចំណត នៅទីធ្លាផ្នែកខាងមុខ ។*

នៅឈរអមច្រកចូលចម្ការ មានដើមត្របែក មកពីតំបន់ត្រូពិក ចំនួន ពីរដើម ។ ព្រាំរបងឈើរស់ត្រូវបានបង្កើតឡើង ដោយដើមត្របែក មកពីតំបន់អនុត្រូពិក (sub-tropical guavas) ។ នៅខាងក្នុងរបងឈើរស់ មានដើមឡាំខ្វាត (loquat trees) ចំនួន បីដើម ដែលមានប្រភពកំណើត នៅប្រទេសចិន ។ នៅតាមផ្លូវដើរ មានដើមក្រូចពោធិ៍សាត់ ដើមអាវ៉ូកាដូ ដើមក្រូចឆ្មាលឿង ដើមក្រូចឆ្មាខៀវ ដើមក្រូចខ្វិច និងដើមម៉ាកាដាមៀ (macadamia trees) ។ នៅជិតច្រកទ្វារ ចេញទៅទីធ្លាផ្នែកខាងក្រោយ មានដើមល្មុតសាប៉ូត [sapote] (នៅខាងស្ដាំ) និងដើមទាប [cherimoya] (នៅខាងឆ្វេង) ។ ដើមទាប ត្រូវបានគេនាំយកមក ពីអាមេរិក ខាងត្បូង ខណៈដែលដើមល្មុតសាប៉ូត មានដើមកំណើត នៅម៉ិកស៊ិកូ កណ្ដាល ។ ពិតជាចម្លែកណាស់ ដែលល្មុតសាប៉ូត និងក្រូច ស្ថិតក្នុងស្រឡាយអំបូរដូចគ្នា ។


*ដើមអាកាស្យា ខ្មៅ*
*(Black Locust Tree)*

## ទីធ្លា នៅផ្នែកខាងក្រោយ (D)

ប្រសិនបើរុក្ខជាតិទាំងនេះ អាចនិយាយបាន មិនជាល្អយ៉ាងណាទេ ! ដើមឈើ ជាច្រើន នៅក្នុងទីធ្លា ផ្នែកខាងក្រោយ ត្រូវបានដាំ នៅពេល រ៉ាហ្វាអ៊ែលឡា & ចន ថែមផល (Rafaela & John Temple) ជាម្ចាស់កាន់កាប់ ផ្ទះធ្វើពីឥដ្ឋ (ក្នុងទសវត្សរ៍ ឆ្នាំ 1840-1860) ។ ដើមឈើពីរបីដើម ត្រូវបានដាំ នៅពេល ម៉ាហ្គារ៉េត & ចូថែម ប៊ិកប៊ី (Margaret & Jotham Bixby) បានមករស់នៅទីនេះ (ក្នុងទសវត្សរ៍ ឆ្នាំ 1860-1880) ។ អ្នកជួល បានដាំដំណាំជាជួរ និងបានចិញ្ចឹមសត្វ នៅទីធ្លាផ្នែកខាងក្រោយ ដើម្បីបំពេញសេចក្ដីត្រូវការ របស់ពួកគេ (ក្នុងទសវត្សរ៍ ឆ្នាំ 1880-1920) ។ ផ្នែកភាគច្រើន នៃសួនច្បារឆ្លុះបញ្ចាំង ពីទេសភាព ដែល រ៉ាហ្វ ខននែល (Ralph Cornell) បានរៀបចំ សម្រាប់ អាវីស & លេវេលលីន ប៊ិកប៊ី ស៊ីញ៉ី [Avis & Llewellyn Bixby Sr.] (ក្នុងទសវត្សរ៍ ឆ្នាំ 1930-1940) ។ រុក្ខជាតិខ្លះ ត្រូវបានបន្ថែម ក្នុងពេលធ្វើការស្ដារសួនច្បារឡើងវិញ (ក្នុងទសវត្សរ៍ ឆ្នាំ 1950-បច្ចុប្បន្ន) ។ *សូមចាប់ផ្ដើមដំណើរ របស់លោកអ្នក តាមទិស ស្របនឹងទ្រនិចនាឡិកា នៅទីធ្លា ផ្នែកខាងក្រោយ ត្រង់ជ្រុង នៅប៉ែកខាងត្បូង នៃរានហាល (មានប្រក់ដំបូល) ។*

***អាកាស្យា ខ្មៅ* (Black Locust) ៖** ដើមអាកាស្យា ខ្មៅ មានដុះជាជួរ នៅជុំវិញ ទីធ្លា ផ្នែកខាងក្រោយ របស់ថែមផល (Temple) ។ ជ្រុងនេះនៃផ្ទះធ្វើពីឥដ្ឋ ត្រូវបានគេសម្អាត នៅទសវត្សរ៍ ឆ្នាំ 1930 ដើម្បីការពារ កូនឈើ របស់ដើមឈើ មួយដើម នៃដើមឈើតាំងពីទសវត្សរ៍ ឆ្នាំ 1840 មក ទាំងនេះ ។ ដើម្បីលើកស្ទួយ ប្រវត្តិរបស់សួនច្បារនេះ ដើមអាកាស្យា ខ្មៅ ជាច្រើនដើម ត្រូវបានដាំ បន្ថែមទៀត នៅទសវត្សរ៍ ឆ្នាំ 1930 ។ *សូមដើរសំដៅទៅ ឯនាយ ចុងរានហាលនោះ ។*

**ទ្រើងវិស្ទើរៀ ដាំគ្របពីលើផ្លូវដើរ (Wisteria Arbor) ៖** មានទ្រើងដើមទំពាំងបាយជូរ គ្របលើផ្លូវដើរ ចំនួនពីរ ដែលបានរៀបចំឡើង នៅសួនច្បារក្នុងអំឡុងទសវត្សរ៍ ឆ្នាំ 1840 ដែលទ្រើងនីមួយៗ នៅអមសងខាងរានហាល ។ ដោយបានបាត់បង់ ជាយូរមកហើយ តាំងពីអំឡុងទសវត្សរ៍ ឆ្នាំ 1930 នោះ ទើបទ្រើងទាំងនោះ ត្រូវបានជំនួស ដោយទ្រើងវិស្ទើរៀ ដាំគ្របពីលើផ្លូវដើរ (Wisteria Arbor) ។ នៅពេលមានផ្ការីក នៅរដូវផ្ការីកម្ដងៗ, ចង្កោមផ្កា ពណ៌ស្វាយ ក្រអូបឈ្ងុយ របស់ដើមវិស្ទើរៀ (Wisteria) ទាក់ទាញ ភ្ញៀវទស្សនា ជាច្រើននាក់ ។ ទោះបីជាវាគ្មានផ្លែក្ដី ក៏ដើមវិស្ទើរៀ (Wisteria) មើលទៅ ហាក់ដូចជា ដើមទំពាំងបាយជូ កាលពីសម័យយូរយាណាស់ មកហើយនោះ ។ *បន្ទាប់ពីទ្រើងនេះទៅ សូមទៅមើល សួនច្បារ ដែលមានថ្នាលលើកថ្នាក់ ឱ្យខ្ពស់ ។*



*ដើម ហ្គីងកូ (Ginkgo Tree)*

**សួនផ្កា ប្រកបដោយម្លប់ត្រឈើងត្រឈៃ ៖** ថ្នាលដាំរុក្ខជាតិ ដែលមានលើកថ្នាក់ ឱ្យខ្ពស់ ត្រូវបានរួមបញ្ចូល នៅក្នុងផែនការទេសភាព កាលពីទសវត្សរ៍ ឆ្នាំ 1930 ដើម្បីផ្គត់ផ្គង់សួនផ្កា ស្រស់បំព្រង (fresh-cut flowers) សម្រាប់ផ្ទះ របស់ អាវីស & លេវេលលីន ប៊ិកប៊ី ស៊ីញ៉ី (Avis & Llewellyn Bixby Sr.) ។ ថ្នាលខ្លះ ត្រូវបានរៀបចំ សម្រាប់ផ្ការីក តាមរដូវ រីឯថ្នាលផ្សេងទៀត ដែលលូតលាស់ នៅក្រោមព្រះអាទិត្យ ។ ចាប់តាំងពីពេលនោះមក ដើមហ្គីងកូ (gingko) និងដើមល្វា (fig trees) មានម្លប់ត្រឈើងត្រឈៃ នៅកន្លែងនេះ ហេតុនេះទើបដើមផ្កា គីរីនៀល (perennials) ដែលធន់នឹងម្លប់ ក្នុងរយៈពេលសមស្រប ត្រូវបានយកដាំ នៅទីនេះ នាពេលសព្វថ្ងៃនេះ ។ *សូមបត់ តាមថ្នាល មានលើកថ្នាក់ឱ្យខ្ពស់នេះ ហើយបន្តដំណើរ របស់លោកអ្នក តាមផ្លូវដី ដែលស្របនឹង ក្លឹបខោនធី ដែលលោកអ្នកអាចមើលឃើញ នៅជិត ដើមហ្គីងកូ (gingko) ។*



*ទីធ្លា នៅផ្នែកខាងក្រោយ (1872)*

**ច្រកទ្វាចូល ក្លឹបខោនធី វើជីនញៀ (Virginia Country Club) ៖** ដោយឈរ បែរខ្នងលោកអ្នក ទៅច្រកទ្វាចូលពណ៌បៃតង (នៅត្រង់កន្លែង ផ្លូវរៀបគដួ កាត់ផ្លូវដីហាប់ណែន) នោះលោកអ្នកនឹងមើលឃើញ វាលស្មៅលាតសន្ធឹង នៅកណ្ដាលបរិវេណ និងផ្ទះធ្វើពីគដួ កម្ពស់ ពីរជាន់ ។ ច្រកទ្វារនេះ ជាច្រកទ្វារផ្ទាល់ខ្លួន របស់ លេវេលលីន ប៊ិកប៊ី ស៊ីញ៉ី (Llewellyn Bixby Sr.) ចូលទៅកាន់ ក្លឹបខោនធី វើជីនញៀ (Virginia Country Club) ដែលនៅទីនោះ ប៊ិកប៊ី (Bixby) ជាសមាជិក សកម្ម មួយរូប ។ នៅខាងស្ដាំដៃ របស់លោកអ្នក មានដើមស្រល់ ស៊ីប្រេស (cypresse) អ៊ីតាលី មួយដើម ក្នុងចំណោម បីដើម ដែលនៅសល់ ពីសួនច្បារដើម របស់ រ៉ាហ្វែលឡា & ចន ថែមផល (Rafaela & John Temple) ។ ទៅហួស ដើមស្រល់នេះ តែបន្តិច មានដើមពោធិ អូស្ត្រាលី (Moreton Bay fig) ដ៏ធំសម្បើមមួយ ដែលមានដើមកំណើត ពីប្រទេសអូស្ត្រាលី យកមកដាំនៅទីនេះ កាលពីដើមទសវត្សរ៍ ឆ្នាំ 1880 ។ *សូមបន្តដំណើររបស់លោកអ្នក ទៅតាមផ្លូវដី ។*



*ឆ្នាំងដែកជើងបី (1938)*

**ឆ្នាំងដែក ជើងបី (Trypot) ៖** នៅក្រោមទង់ជាតិអេស្ប៉ាញ និង ទង់ជាតិម៉ិចស៊ិកូ, សេដ្ឋកិច្ច របស់ អាល់តា កាលីហ្វ័រញ៉ា (Alta California) ពឹងផ្អែកលើ ការចិញ្ចឹមពាហនៈ ឬ «ពាណិជ្ជកម្ម ស្បែក និងខ្លាញ់ពាហនៈ» ។ ស្បែកគោ ត្រូវបានគេយកទៅធ្វើ ស្បែកជើងកវែង និងផលិតផលធ្វើពីស្បែក ផ្សេងៗ ទៀត ។ ខ្លាញ់គោ ឬខ្លាញ់ពាហនៈ ត្រូវបានគេយកទៅដាំ នៅក្នុងឆ្នាំងដែកជើងបី (trypots) ហើយយកទៅធ្វើ ទៀន និងសាប៊ូ ។ ដោយរួមបញ្ចូល ប្រវត្តិទីតាំង ទៅក្នុងរចនាបទទេសភាព របស់គាត់, រ៉ាហ្វ ខននែល ស្ថាបត្យករទេសភាព (landscape architect Ralph Cornell) បានដាក់ ឆ្នាំងដែកពីសម័យកាល ឆ្នាំ 1840 នេះ ទៅក្នុងសួនផ្កា (cut-flower garden) សល់ពីសម័យទសវត្សរ៍ ឆ្នាំ 1930 ។ សាលាក្រុងបានផ្លាស់ទីវាមកទីនេះ ។ *សូមរកមើលផ្លូវដើរ នៅខាងឆ្វេងដៃ ដែលនាំទៅដល់ នាឡិកាព្រះអាទិត្យ ដែលលោកអ្នក មើលឃើញ ហួសពីឆ្នាំងដែក ជើងបីនោះ ។*

**សួនរុក្ខជាតិមានក្លិនឈ្ងុយ (Herb) ៖** ដោយបានដាំដុះ ដោយអ្នកស្ម័គ្រចិត្ត មកពីសម្ព័ន្ធយុវជន ឡុងប៊ិច នៅទសវត្សរ៍ ឆ្នាំ 1980, សួនរុក្ខជាតិមានក្លិនឈ្ងុយនេះ ទ្រទ្រង់ដល់ កម្មវិធីទស្សនាចរណ៍ របស់សាលាជាម្ចាស់ជ័យលាភី របស់យើង ។ វាត្រូវបានបែងចែក ចេញជា បួនផ្នែក (ផ្នែកចំណីអាហារ ផ្នែកឱសថ ផ្នែកជ្រលក់ពណ៌ ផ្នែកក្លិន) ដើម្បីបង្ហាញ ពីរុក្ខជាតិមានក្លិនឈ្ងុយ ដែលមានប្រយោជន៍ ។ សួនរុក្ខជាតិមានក្លិនឈ្ងុយនេះ ស្ថិតនៅជុំវិញ នាឡិកាព្រះអាទិត្យ ដែលត្រូវបានស្ថាបនាឡើង ឧទ្ទិសដល់ ចូថែម ប៊ិកប៊ី (Jotham Bixby) ។ *សូមដើរទៅលើ ដើម្បីមើល ប៉មទឹក ។*



*ប៉មអាងទឹក (1921)*

**ប៉មទឹក ៖** ទឹកស្អាត គឺជាស្នូលនៃជីវិតរស់នៅ ។ ពលករកសិដ្ឋានពីដើមឡើយ បូមទឹកចេញពីទន្លេ នៅក្បែរនោះ ដោយប្រើ ប្រព័ន្ធកម្លាំងសម្ពាធរុញទឹក (water ram) ។ វាមានប្រសិទ្ធភាព រហូតដល់ពេលគ្រោះរាំងស្ងួត បានធ្វើឱ្យទន្លេស្រកទឹក ។ ក្នុងអំឡុងទសវត្សរ៍ ឆ្នាំ 1860 គេជីកអណ្ដូង ថ្មីមួយ ។ វាមាន ម៉ាស៊ីនរុញដោយកម្លាំងខ្យល់ ដើម្បីបូមទឹកឡើងទៅអាងរក្សាទឹក ឬ ប៉មទឹក ។ កសិដ្ឋាន រ៉ាញ់ឆូ ឡូស សឺរីតូស (Rancho Los Cerritos) ត្រូវបានតភ្ជាប់ នឹងបណ្ដាញទឹក របស់ទីក្រុង នៅទសវត្សរ៍ ឆ្នាំ 1930 ។ *សូមបន្តដំណើរ តាមផ្លូវដី ទៅមុខទៀត ដើម្បីទៅមើល ឡចង្ក្រានដី (Horno) ។*

**ឡចង្ក្រានដី (Horno) ៖** សំណង់ មានរាងដូចសម្បុកឃ្មុំ ត្រូវបានបង្កើតឡើង ពីគដួធ្វើពីដី ហាលថ្ងៃ នៅទសវត្សរ៍ ឆ្នាំ 1990 ។ វាមានរាងស្រដៀងនឹង ឡដី (ចង្ក្រាន) ដែលត្រូវបានប្រើប្រាស់ ដើម្បីដុតនំ នៅទីនេះ កាលពីអំឡុងទសវត្សរ៍ ឆ្នាំ 1840 ។ ឡចង្ក្រានដី របស់ រ៉ាហ្វែលឡា & ចន ថែមផល (Rafaela & John Temple) នៅតែត្រូវបានប្រើប្រាស់ ដោយចុងភៅ របស់កសិដ្ឋាន នៅក្នុងអំឡុងទសវត្សរ៍ ឆ្នាំ 1870 ។ នៅពេលនោះ ពួកគេក៏អាចប្រើប្រាស់ ចង្ក្រានដុតអុស នៅក្នុងផ្ទះបាយ ផងដែរ ។ *សូមត្រឡប់ក្រោយវិញ ដើម្បីទៅ ផ្ទះធ្វើពីគដួ ។*

**ផ្លែទទឹម ៖** ដើមផ្លែទទឹម ចំនួន បីដើម នៅសល់តាំងពីសម័យសួនច្បារដើម របស់ប្រាសាទ (Temples' original garden) នេះ ។ ប្រសិនបើអ្នកពិនិត្យមើល ថ្នាលរុក្ខជាតិ នៅខាងស្ដាំដៃលោកអ្នក ដែលមានមុំផ្លូវដើរ នៅសេសសល់នោះ លោកអ្នកអាចមើលឃើញ ដើមទទឹមទ្រេត មួយដើម ។ ម្ចាស់ប្រាសាទ នៃអចលនទ្រព្យនេះ មានអាយុកាល តាំងពីទសវត្សរ៍ ដែលម្ចាស់ក្សត្រី វិកតូរីយ៉ា (Queen Victoria) បានឡើងសោយរាជ្យ នៅប្រទេសអង់គ្លេស (អំឡុងទសវត្សរ៍ ឆ្នាំ 1840) ។ គួរជាទីចាប់អារម្មណ៍ មនុស្សនៅសម័យនោះ ដែលសព្វថ្ងៃនេះ យើងហៅថា «អ្នកសម័យវិកតូរីយ៉ា ("Victorians")» បានបង្កើតភាសា ដែលតំណាងដោយផ្កា ។ ចំពោះអ្នកសម័យវិកតូរីយ៉ា គេនិយាយថា ផ្កាទទឹម តំណាងឱ្យ «សម្រស់ពេញវ័យ» ។ ផ្លែទទឹមទាំងនេះ មើលទៅសមសួនដល់ហើយ ! *ច្រកចេញពីសួនច្បារ គឺនៅជិត រានហាល ។*

## ទីធ្លាផ្នែកខាងមុខ (E)

ទីចំណត នៅទីធ្លាផ្នែកខាងមុខ ត្រូវបានបន្ថែម នៅទសវត្សរ៍ ឆ្នាំ 1930 ដើម្បីទទួល យានជំនិះភ្ញៀវ របស់ អាវីស & លេវេលលីន ប៊ិកប៊ី ស៊ីញ៉ី (Avis & Llewellyn Bixby Sr.) ។ នៅផ្នែកខាងឆ្វេងទ្វាចូល មានស្លាកបង្ហាញពី ព្រំដី កាលពីសតវត្សរ៍ទី 19 របស់កសិកដ្ឋាន រ៉ាញ់ឆូ សឺរីតូស (Rancho Los Cerritos) និង កសិដ្ឋាននៅក្បែរគ្នានោះ មានឈ្មោះថា រ៉ាញ់ឆូ ឡូស អាឡាមីតូស (Rancho Los Alamitos) ។ កសិដ្ឋានទាំងពីរនេះ ពីដើមឡើយ ជាផ្នែករបស់កសិដ្ឋាន រ៉ាញ់ឆូ ឡូស នីតូស (Rancho Los Nietos) ដែលត្រូវបានប្រគល់ឱ្យ ទាហានអេស្ប៉ាញ ឈ្មោះ ម៉ាន្វអែល នីតូ កាលពីឆ្នាំ 1784 នៅពេលអាល់តា កាលីហ្វ័រញ៉ា (Alta California) ស្ថិតនៅក្រោមចក្រភពអេស្ប៉ាញ ។ ដើមឈើខ្ពស់បំផុត នៅទីធ្លាខាងមុខ គឺដើមក្រូច អូសាហ្ស (Osage orange) ដែលមានដើមកំណើត នៅអាកខានសាស់ និង តេចសាស់ ។ ប្រជាជន អូសាហ្ស (Osage) បានប្រើប្រាស់ផ្លែឈើ ដើម្បីជ្រលក់ពណ៌ក្រណាត់ ជាយូរយារមកហើយ ។ ដោយមិនសូវឃើញមាន នៅកាលីហ្វ័រញ៉ា ប៉ែកខាងត្បូង, ដើមឈើនេះ មានអាយុកាល តាំងពីសម័យសួនច្បារដើម របស់ប្រាសាទនេះ ។
ភ្ញៀវសម័យទំនើប និយាយថា ផ្លែរបស់វា មើលទៅដូចជា «ខួរក្បាល ពណ៌បៃតង» ។ *សូមសង មគ្គុទេសក៍នេះ ទៅមជ្ឈមណ្ឌលទទួលភ្ញៀវវិញ ។*

**សូមអរគុណដែលបានរុករកមើលរ៉ាញ់ឆូ ឡូស សឺរីតូស (Rancho Los Cerritos) នៅថ្ងៃនេះ !**

ព័ត៌មានត្រឡប់របស់លោកអ្នក មានតម្លៃណាស់ ៖ www.RanchoLosCerritos.org/Visitor-Survey